# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 945

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ពង្រឹងការអភិរក្សជីវៈចម្រុះ និងព្រៃស្អកកាបូននៃប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជាតាមរយៈកិច្ចសហការគ្រប់គ្រង និងអនុវត្តបង្ហាញពីការអភិរក្សតំបន់ទេសភាពខាងកើតទន្លេមេគង្គ ហៅកាត់ថាគម្រោង "CAMPAS"

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 28/06/16 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/09/21 |

៣. ចំណាយគម្រោងសរុប $4,718,182

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

| | |
|---|---|
| RESPONSIBLE UNIT | General Secretariat for Sustainable Development (GSSD), MoE |
| អង្គភាពទទួលខុសត្រូវ | អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងកម្មវិធីអភិរក្សជីវៈចម្រុះថ្នាក់ជាតិ ការបញ្ជ្រាបតម្លៃនៃជីវៈចម្រុះ និងតំបន់ការពារធម្មជាតិទៅក្នុងផែនការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុង និងនៅជុំវិញតំបន់ការពារធម្មជាតិក្នុងតំបន់គោលដៅ ក៏ដូចជាការបង្កើនការតភ្ជាប់តំបន់ ទេសភាព។ នៅចុងក្រោយក៏រួមចំណែកដល់ការអភិរក្សព្រៃស្អកកាបូនដែលជាជម្រើសយន្តការហិរញ្ញវត្ថុមួយសម្រាប់ ជំរុញការចូលរួមអភិរក្សព្រៃឈើ និងលើកកម្ពស់ជីវភាពប្រជាសហគមន៍ផងដែរ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

មណ្ឌលគីរី,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងមានគោលដៅ ដើម្បីធ្វើឱ្យប្រសើរឡើងនូវនិរន្តរភាពនៃប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជា បញ្ជ្រាបជីវៈចម្រុះទៅក្នុងផលិតកម្មតំបន់ទេសភាព និងលើកកម្ពស់ការអភិរក្សនៃការស្តុកកាបូន។

គម្រោងមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជា និងធានា បាននូវព្រៃកាបូន តាមរយៈការលើកកម្ពស់កិច្ចសហការអន្តរវិស័យ ការតភ្ជាប់តំបន់ទេសភាព និងការគ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តរភាព។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោង CAMPAS គឺជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយតំបន់ជីវៈចម្រុះដែលផ្តោតការយកចិត្តទុកដាក់ដោយGEF សំដៅធ្វើអោយប្រសើរឡើងនូវនិរន្តរភាពនៃប្រព័ន្ធការពារតំបន់ - លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងលើផ្ទៃដីការពារជាង 4,5 លានហិកតា ដោយពង្រឹងប្រព័ន្ធអនុវត្តច្បាប់ជាតិរបស់កម្ពុជា ការបង្កើតនិងអនុវត្តបង្ហាញការសម្របសម្រួល ធ្វើផែនការ ការគ្រប់គ្រងព័ត៌មាន ការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុ ដែលបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ស្ថាប័នចំនួនបីដែលមិនសូវស៊ីសង្វាក់គ្នា និងការចែករំលែកព័ត៌មាននៅមានកម្រិត។

ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថាជាប្រទេសអាទិភាពមួយសម្រាប់ការអភិរក្សជីវៈចម្រុះ ដោយមានតំបន់ការពារធម្មជាតិជាសកលរួមមាន តំបន់ព្រៃស្ងួតផ្នែងខាងក្រោមទន្លេមេគង្គ តំបន់ព្រៃលិចទឹកទន្លេរមេគង្គ និងបឹងទន្លេសាប តំបន់ព្រៃជួរភ្នំក្រវាញ និងឈូងសមុទ្រថៃ។ ធនធានធម្មជាតិដ៏សម្បូរបែបរបស់ប្រទេសនេះ រួមមានបឹងត្រីធម្មជាតិ ធំជាងគេក្នុងពិភពលោក តំបន់ព្រៃឈើធំជាងគេនៅមេគង្គនិងទន្លេស្មុកស្មាញ និងតំបន់ដែលមានសល់ព្រៃធម្មជាតិ ធំជាងគេនៅទ្វីបអាស៊ី។

កម្ពុជាក៏ជាជម្រកនៃប្រភេទសត្វកំពុងទទួលរងការគំរាមកំហែងជាសកលប្រមាន១,៦% នៃប្រភេទសត្វបញ្ជីក្រហម IUCN រាប់បញ្ចូលទាំង២,៥% នៃ ថនិកសត្វទទួលរងការគំរាមកំហែងនៅលើពិភពលោក ២% នៃប្រភេទបក្សីទទួលរងការគំរាមកំហែងនៅលើពិភពលោក និង៥%នៃសត្វល្មូនទទួលរងការគំរាមកំហែងនៅលើ ពិភពលោកផងដែរ។

គម្រោងរៀបចំឡើងមានលទ្ធផលរំពឹងទុកសំខាន់ពីរ ដែលទីមួយផ្តោតលើការអនុវត្តនៅថ្នាក់ជាតិដែលគ្រោងចំណាយ ថវិកាប្រមាណ 2,980,730 (ប្រភពពីUNEP/GEF) និងគាំទ្រការអនុវត្តលទ្ធផលរំពឹងទុកនៅទីទាំងអនុវត្តគម្រោង។ នៅកំរិតថ្នាក់ជាតិ គម្រោងCAMPAS មានលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៣ ដែលនាំទៅដល់ការពង្រឹងឯកភាព និងគាំទ្រដល់យន្តការតំបន់ការពារទេសភាព និងការគ្រប់គ្រងព្រៃឈើ។ កត្តាទាំងនេះនឹងអនុវត្តតាមរយៈការ ប្រាស្រ័យទាក់ទង និងផ្តល់ការយល់ដឹង ការពង្រឹងការគ្រប់គ្រងតំបន់ការពារដោយមានការចូលរួមសហការណ៍ពី អន្តរស្ថាប័ន និងការអនុវត្តបង្ហាញពីជម្រើសហិរញ្ញវត្ថុដែលមាននិរន្តរភាព។ ដោយឡែកនៅទីតាំងអនុវត្តគម្រោង លទ្ធផលរំពឹងទុករបស់គម្រោងនឹងបង្កើតវិធីសាស្ត្ររៀបចំផែនការនៅថ្នាក់មូលដ្ឋានសម្រាប់តំបន់ការពារទេសភាព ខាងកើតទន្លេមេគង្គដែលរួមបញ្ចូលតំបន់ការពារ និងតំបន់អភិរក្សជីវៈចម្រុះ។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោង CAMPAS នឹងរួមចំណែកដល់ការសម្រេចបានលទ្ធផលរំពឹងទុករបស់ UNDAF កម្ពុជា ឆ្នាំ 2011-2015 ដែលមានលទ្ធផលពាក់ព័ន្ធនឹង៖

- លទ្ធផលរំពឹងទុក 1.2៖ បរិស្ថាននិងការអភិវឌ្ឍដោយចីរភាព: ស្ថាប័នជាតិ រដ្ឋបាលមូលដ្ឋាននិងវិស័យឯកជនអាចជានាបាននូវការប្រើប្រាស់ធនធានធម្មជាតិ (ទេសាទ ព្រៃឈើ ព្រៃកោងកាង ដី និងតំបន់ការពារ) ប្រកបដោយនិរន្តភាព តាមរយៈបច្ចេកវិទ្យាស្អាត និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ
- ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិតាមវិធីសាស្ត្រមានការចូលរួមពីសហគមន៍មូលដ្ឋានដើម្បីលើកកម្ពស់ជីវភាពរស់នៅដែល ត្រូវបានបញ្ជ្រាបទៅក្នុងផែនការអភិវឌ្ឍជាតិនិងថ្នាក់ជាតិដើម្បីលើកកម្ពស់ការផ្សារភ្ជាប់ការកាត់បន្ថយភាពក្រីក្រ និងបរិស្ថាន
- សមត្ថភាពនៃវិស័យសាធារណៈនិងឯកជនត្រូវបានពង្រឹងដើម្បីលើកកម្ពស់បច្ចេកទេសស្អាតស្អំនិងបរិស្ថាន និងអន្តរាគមន៍សម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងការបង្កើនផលិតភាពធនធាន។

គម្រោងនេះនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារជាតិ និងកម្មវិធីអភិរក្សជីវៈចម្រុះថ្នាក់ជាតិ ការបញ្ជ្រាបតម្លៃនៃជីវៈចម្រុះនិង តំបន់ការពារនៅក្នុងផែនការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងនិងនៅជុំវិញតំបន់ការពារ ក៏ដូចជាតាមរយៈការបង្កើនការតភ្ជាប់តំបន់ទេសភាព។ នៅចុងក្រោយក៏រួមចំណែកដល់ការអភិរក្សឃ្លាំងកាបូនព្រៃឈើនិងការប្រមូលឧស្ម័នកាបូនដែលស្របតាមលទ្ធផលរបស់ UNDAF ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ក្រសួងបរិស្ថាន (MoE) ជាទីភ្នាក់ងារប្រតិបត្តិជាតិសម្រាប់គម្រោងមានយុត្តាធិការលើតំបន់ការពារដែលគ្របដណ្តប់ដោយច្បាប់ស្តីពីតំបន់ការពារនិងជាស្ថាប័នបង្គោលជាតិសម្រាប់ GEF CBD, Ramsar Convention និងUNFCCC នៅក្នុងប្រទេសកម្ពុជា។ គម្រោងនេះនឹងធ្វើការយ៉ាងជិតស្និទ្ធលើការអនុវត្តបង្ហាញសកម្មភាពពាក់ព័ន្ធតំបន់ទេសភាពជាមួយអ្នកពាក់ព័ន្ធជាច្រើនដែលដំបូងចូលរួមតាមរយៈ អនុគណៈកម្មាធិការថ្នាក់ខេត្តស្តីពីព្រៃឈើជីវៈចម្រុះ និងការអភិវឌ្ឍន៍ដែលមានសមាជិកមកពីការិយាល័យរដ្ឋបាលខេត្ត មន្ទីរបរិស្ថាន មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ អង្គការពាក់ព័ន្ធ និងតំណាងរដ្ឋបាលស្រុក។ អនុគណៈកម្មាធិការនេះដើរតួនាទីជាកន្លែងសម្រាប់ពិភាក្សា បណ្តុះបណ្តាលពង្រឹងសមត្ថភាព និងរៀបចំសកម្មភាពនានាសំដៅឈានដល់ការអភិវឌ្ឍន៍ដោយចីរភាពនៅកម្រិត ថ្នាក់ខេត្ត។ គម្រោងCAMPAS នឹងជួយកែសម្រួលការងារក្នុងអាណត្តិរបស់គណៈកម្មាធិការដើម្បីជួយការពារតំបន់ ទេសភាពនៅខាងកើតទន្លេមេគង្គ។ ការិយាល័យរដ្ឋបាលខេត្តនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលក្នុងការរៀបចំ spatial planning និងកៀរគរការចូលរួមរបស់វិស័យឯកជននៅក្នុងការផ្តល់ហិរញ្ញប្បទានគាំទ្រតំបន់ការពារ។

ការិយាល័យរដ្ឋបាលខេត្តនឹងដឹកនាំមន្ទីរពាក់ព័ន្ធទាំងអស់ដែលជាប់ពាក់ព័ន្ធចក្ខុវិស័យ នៃការអភិវឌ្ឍន៍របស់ខេត្ត និងមានលទ្ធភាពទាក់ទងជាមួយវិស័យពាណិជ្ជកម្មនិងដៃគូពាក់ព័ន្ធផ្សេងទៀតដើម្បីស្វែងរកការឧបត្ថម្ភថវិកា ដើម្បីបង្កើនប្រភពហិរញ្ញវត្ថុសម្រាប់តំបន់ការពារ។ សហគមន៍ព្រៃឈើនិងនេសាទថ្នាក់ខេត្ត គឺជាអ្នកពាក់ព័ន្ធអនុវត្តគម្រោង ផងដែរដោយមានបណ្តាញសហគមន៍និងគណៈកម្មាធិការផែនការខេត្ត និងក្រុមការងារគាំទ្រដល់សហគមន៍ព្រៃឈើ និងជលផល។ ពួកគេក៏មានមុខងារសំខាន់ក្នុងការដាក់បញ្ចូលវិធីសាស្ត្រគ្រប់គ្រងតំបន់ទេសភាព ការធ្វើផែនទីប្រព័ន្ធ អេកូឡូស៊ី គោលការណ៍ស្តីពីការរស់នៅប្រកបដោយនិរន្តភាព គោលការណ៍របស់សហគមន៍ព្រៃឈើនិងនេសាទ ការប្រើប្រាស់ដីធ្លីនិងផែនការអភិវឌ្ឍខេត្តនិងប្រតិបត្តិការសហគមន៍និងគ្រប់គ្រងធនធានធម្មជាតិ។ អង្គការសង្គមស៊ីវិលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់ការអនុវត្តគម្រោងក្រោមការសម្របសម្រួលជាទូទៅរបស់ក្រសួងបរិស្ថាន និងក្នុងការទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសហគមន៍ព្រៃឈើនិងនេសាទ ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ការពិពណ៌នា

ផលប៉ះពាល់បរិស្ថាន

A. គម្រោង CAMPAS នឹងត្រូវការទីកន្លែងបណ្តុះអាសន្នដើម្បីបំពេញការងារប៉ុន្តែទីតាំងទាំងនោះអាចត្រូវបាន មានរួចរាល់ដោយអង្គការដៃគូឬភ្នាក់ងារអនុវត្តគម្រោង

B. គម្រោង CAMPAS នឹងមិនបណ្តាលឱ្យខូចខាតដល់មុខងារប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចតាមរយៈការស្តារបនាគម្រោងហេដ្ឋារចនាសម្ព័ន្ធនោះទេ ដោយគម្រោងមិនមានសមាសភាពណាពាក់ព័ន្ធការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

C. ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់អនុវត្តគម្រោង CAMPAS នឹងមិនខូចខាត។ គោលបំណងនៃគម្រោងដើម្បីពង្រឹងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីទាំងនេះដើម្បីគាំទ្រដល់និរន្តរភាពរបស់ពួកគេ

D. គម្រោង CAMPAS នឹងមិនធ្វើឱ្យអន់ថយដល់ប្រព័ន្ធអេកូឡូស៊ីតាមរយៈការអនុវត្តបង្ហាញនៅតំបន់ទេសភាព

E. គម្រោង CAMPAS នឹងមិនពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលដល់ការកើនឡើងខ្ពស់ និងលំហូរទឹកជំនន់ដោយរួមបញ្ចូលទាំងពីប្រភពទឹកកខ្វក់ជាបណ្តោះអាសន្នឬជាអចិន្រ្តៃយ៍

F. គម្រោង CAMPAS នឹងមិនបណ្តាលឱ្យមានបំពុលខ្យល់ ដី សំណឹកដី ការកើនឡើងបរិមាណទឹក ផលិតកម្មទឹក មានគ្រោះថ្នាក់ការប្រើប្រាស់ថ្នាំបំពុល  មានសំលេងរំខាន ឬចរាចរណ៍ហួសប្រមាណ

G. គម្រោង CAMPAS នឹងមិនបង្កឱ្យមានការគំរាមកំហែងដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់តាមរយៈប្រភេទសត្វរាត ត្បាតនោះទេ ដោយសារនឹងលើកកម្ពស់ការអនុវត្តគោលការណ៍អភិរក្សរបៀងជីវៈចម្រុះ ដើម្បីបង្កើនការស្តារឡើងវិញ ប្រភេទក្នុងស្រុក

H. គម្រោង CAMPAS នឹងមិនបណ្តាលឱ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់លើកលែងតែការដឹកជញ្ជូនធម្មតា ប៉ុន្តែគម្រោងនេះគឺដើម្បីពង្រឹងការរក្សាទុកកាបូន។

I. នៅគ្រប់ដំណាក់ទាំងអស់ តាមដែលអាចអនុវត្ត គម្រោង CAMPAS នឹងលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកវិទ្យាដែលមិនប៉ះពាល់ដល់បរិស្ថាននៅថ្នាក់មូលដ្ឋានជាមួយរដ្ឋាភិបាល អង្គការពាក់ព័ន្ធនិងអ្នកពាក់ព័ន្ធសហគមន៍

ផលប៉ះពាល់សង្គម

A. គម្រោង CAMPAS នៅគ្រប់ដំណាក់កាលអនុវត្តទាំងអស់ នឹងគោរពគោលសិទ្ធិមនុស្សជាអន្តរជាតិរួមទាំង ភាពថ្លៃថ្នូរ វប្បធម៌ប្រពៃណីនិងលក្ខណៈពិសេសនៃសិទ្ធិរបស់ជនជាតិដើមភាគតិច

B. គម្រោង CAMPAS នឹងមិនបង្កឱ្យមានបញ្ហាក្នុងសង្គមឬទំនាស់ទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី និងលទ្ធភាពទទួលបានធនធានទេទោះបីជាវានឹងដោះស្រាយបញ្ហាជីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ

C. គម្រោង CAMPAS នឹង រួមបញ្ចូលវិធានការនានាដើម្បីអនុញ្ញាត្តិឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ។ នៅកន្លែងអនុវត្តបង្ហាញគម្រោងនឹងផ្តោតសំខាន់លើការចូលរួមរបស់ភាគីពាក់ព័ន្ធ។

D. គម្រោង CAMPAS មិនមានសកម្មភាពអនុ ដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លីឬធនធានដែលជាប្រយោជន៍ស្របច្បាប់ទោះរបស់សហគមន៍ បើទោះបីជានឹងមានសកម្មភាពពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនិងការអភិរក្សក៏ដោយ

E. គម្រោង CAMPAS នឹងមិនរួមបញ្ចូលបច្ចេកវិទ្យាដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លីដែលអាចផ្លាស់ប្តូរសកម្មភាពសង្គមនិងសេដ្ឋកិច្ចបច្ចុប្បន្នឡើយ

F. គម្រោង CAMPAS នឹងមិនបណ្តាលឱ្យមានការផ្លាស់ប្តូរទីលំនៅឬការតាំងទីលំនៅជាថ្មីដោយបង្ខំរបស់សហគមន៍

មូលដ្ឋានឬបណ្តុលឱ្យមានការធ្វើចំណាកស្រុក។

G. គម្រោង CAMPAS នឹងរួមបញ្ចូលនូវវិធានការវាស់វែងពីតម្លាភាពដើម្បីចៀសវាងអំពើពុករលួយ និងលើកកម្ពស់ការប្រើប្រាស់ហិរញ្ញវត្ថុនិងធនធានដោយសមធម៌

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការកាត់បន្ថយ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
| --- | --- | --- |
| **១៤. ការកាត់បន្ថយការបញ្ចេញឧស្ម័ន** | 32 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងCAMPAS នឹងគិតគូរពេលលេញលើតម្រូវការសម្រាប់សមភាពយេនឌ័រនៅគ្រប់ដំណាក់កាលអនុវត្តគម្រោង នៅគ្រប់ផ្នែក និងគ្រប់កម្រិតដោយរួមបញ្ចូលទាំងដំណើរការវាយតម្លៃការចូលរួមរបស់ស្ត្រី និងបុរសក្នុងដំណើរការ ធ្វើផែនការ។ គម្រោងនឹងធ្វើឱ្យប្រាកដថារាល់កង្វល់ និងបទពិសោធន៍នៃអ្នកពាក់ព័ន្ធទាំងអស់រួមមានស្ត្រី និងបុរស ត្រូវបានដាក់បញ្ចូលក្នុងដំណាក់កាលរៀបចំ អនុវត្ត ត្រួតពិនិត្យ វាយតម្លៃ លើលទ្ធផលគម្រោងសំដៅសម្រេចឱ្យបាននូវសមភាពយេនឌ័រ។

គម្រោងក៏នឹងធ្វើការវាយតម្លៃលើផលប៉ះពាល់រវាងបុរស និងស្ត្រីនៅរាល់សកម្មភាពដែលបានគ្រោងទុកដោយរួមបញ្ចូលទាំងក្របខណ្ឌច្បាប់ គោលនយោបាយ ឬកម្មវិធីផ្សេងៗនៅគ្រប់ផ្នែក និងគ្រប់កម្រិត។ ឧទាហរណ៍ដូចជាសកម្មភាព រួមមាន៖ ១) រៀបចំកិច្ចប្រជុំដាក់លាក់សម្រាប់ក្រុមស្ត្រី វេទិការ ឬការពិភាក្សាក្រុម (FGDs) ដែលផ្តល់ឱកាសឱ្យពួកគាត់ អាចសំដែងមតិ កង្វល់ សំណូមពរ នៅមុនកិច្ចប្រជុំរួមដែលមានការចូលរួមទាំងបុរស និងស្ត្រី ២) គាំទ្រនិងពង្រឹង សមត្ថភាពរបស់ក្រុមស្ត្រី បណ្តាញស្ត្រីដែលមានស្រាប់នៅក្នុងតំបន់គោលដៅ ដែលនាំឱ្យពួកគាត់អាចបង្ហាញពីភាព ជាអ្នកដឹកនាំរបស់ពួកគាត់ លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនឥទ្ធិពលក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាទាក់ទង បញ្ហាបំរែបម្រួលអាកាសធាតុ និងកម្មវិធីREDD+ និង ៣) បង្កើនភាពអង្គអាចរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការ ធ្វើឱ្យប្រសើរឡើងជីវៈភាពរស់នៅ។ PMU បានបង្កើតមគ្គុទេសន៍ស្តីពីយេនឌ័រ សម្រាប់គម្រោងដើម្បីធ្វើឱ្យប្រាកដថា បញ្ហាយេនឌ័រត្រូវមានដាក់បញ្ចូលក្នុងផ្នែកនៃដំណើរការសំខាន់ៗ ត្រួតពិនិត្យនិងធ្វើរបាយការណ៍ ដោយរួមបញ្ចូលក្នុង វគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ វេទិការ។ល។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ផ្អែកតាមគោលនយោបាយដែលមានស្រាប់របស់GEF អង្គការ UNEP គឺជាភ្នាក់ងារអនុវត្តសម្រាប់គម្រោងនេះ

២៧. ស្ថានភាពនៃការអនុវត្តគម្រោង (ពិពណ៌នាសង្ខេបអំពីខ្សែនៃភាពរបស់គម្រោងនិងបង្ហាញអត្ថបទនានាដែល បណ្តាល ឲ្យមាន ការពន្យារពេលក្នុងការអនុវត្តគម្រោង។)

ដែលមានតួនាទីត្រួតពិនិត្យ និងផ្តល់ជំនួយបច្ចេកទេសដើម្បីធានាបានភាពស៊ីសង្វាក់គ្នារវាងកម្មវិធី និតិវិធី និងដំណើរ ការត្រួតពិនិត្យពីប្រសិទ្ធភាពនៃការសម្រេចបាននៃសមិទ្ធផលរំពឹងទុករបស់គម្រោងស្របតាមគោលការរបស់របស់GEF និងUNEP។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងបរិស្ថាន (MoE) នឹងដើរតួជាភ្នាក់ងារប្រតិបត្តិដែលទទួលខុសត្រូវ ក្នុងការអនុវត្តគម្រោងឱ្យស្របតាមគោលបំណង លទ្ធផលរំពឹងទុក និងសូចនាករណ៍ដែលមានកំណត់នៅក្នុងឯកសារ គម្រោង។ ក្រសួងនឹងអនុញ្ញាតឱ្យUNEP អាចមានលទ្ធភាពទទួលបានរាល់ព័ត៌មានដែលជាប់ព័ន្ធនិងគម្រោង ដើម្បី អាចបំពេញលក្ខខណ្ឌរបស់GEF។ ការគ្រប់គ្រង និងការចុះកិច្ចសន្យានឹងធ្វើឡើងតាមរយៈអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD-MoE) ទៅកាន់ភ្នាក់ងារអនុវត្ត ដោយរួមមានស្ថាប័នរដ្ឋ អង្គការមិនមែន រដ្ឋាភិបាល និងវិស័យឯកជនផ្សេងទៀត។ ដើម្បីសម្របស្រួលពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ សម្ព័ន្ធនៃ អង្គការមិនមែនរដ្ឋាភិបាលនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រគម្រោងCAMPAS និងការផ្តល់ហិរញ្ញវត្ថុ ហើយតាមរយៈយន្តការនេះអាចធ្វើឱ្យការសម្របសម្រួលអនុវត្តសកម្មភាព នៅទីតាំងអនុវត្តគម្រោងកាន់តែមាន ស័ក្តិសិទ្ធភាពក្នុងការផ្សារភ្ជាប់ទៅកាន់សកម្មភាពហិរញ្ញវត្ថុរួមគ្នា។ ក្រសួងបរិស្ថាន (MoE) ជាទីភ្នាក់ងារប្រតិបត្តិជាតិ សម្រាប់គម្រោងមានយុត្តាធិការលើតំបន់ការពារដែលគ្រប់ដណ្តប់ដោយច្បាប់ស្តីពីតំបន់ការពារនិងជាស្ថាប័នបង្គោលជាតិសម្រាប់ GEF CBD, Ramsar Convention និងUNFCCC នៅក្នុងប្រទេសកម្ពុជា។

រចនាសម្ព័ន្ធគ្រប់គ្រងគម្រោងគឺផ្អែកលើភាពជាម្ចាស់របស់រដ្ឋាភិបាល និងស្របទៅនឹងការរៀបចំស្ថាប័នរបស់រដ្ឋាភិបាល ដែលមានស្រាប់ ដើម្បីធានាពីនិរន្តរភាព និងឆ្លើយតមទៅនឹងលទ្ធផលនៃគម្រោង។ គម្រោងនឹងធ្វើរបាយការណ៍ទៅ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាស្ថាប័នរដ្ឋថ្នាក់កំពូលសម្រាប់ការសម្របសម្រួលផ្នែកជីវៈចម្រុះ នៅកម្ពុជា។ លេខាធិការដ្ឋានជីវៈចម្រុះជាតិ ត្រូវបានបង្កើតនៅឆ្នាំ២០០១ ដើម្បីសម្របសម្រួល ការអនុវត្តការធ្វើ បច្ចុប្បន្នភាព NBSAP។ គម្រោងនឹងមានទីតាំងក្នុងនាយកដ្ឋានជីវៈចម្រុះនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព ដែលមានទីតាំងក្នុងក្រសួងបរិស្ថាន។

ការអនុវត្តគម្រោងគឺស្ថិតក្នុងដំណាក់កាលរៀបចំកិច្ចសន្យាអនុវត្ត និងចរចារជាមួយស្ថាប័នរដ្ឋ និងអង្គការមិនមែន រដ្ឋាភិបាលសំខាន់ៗ ដែលPMU បានទទួលដំណើរគម្រោងចំនួន៨ពីស្ថាប័ននិងអង្គការដៃគូ ដែលក្នុងនោះរួមមាន៖ ១)អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ២) នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាដ្ឋានក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព ៣) អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ៤)អង្គការWWF ៥)អង្គការWCS ៦)អង្គការBirdLife International ៧)អង្គការERECON និង ៨)អង្គការLive and Learn ។ សំណើគម្រោងរួមបញ្ចូលទាំងពង្រាងថវិកា លម្អិត និងផែនការសកម្មភាពដែលត្រូវអនុវត្តសម្រាប់ឆ្នាំ២០១៨ (ឆ្នាំទី២នៃការអនុវត្តគម្រោង) និងសម្រាប់រយៈពេល គម្រោងឆ្នាំ ២០១៨-២០២១ (ឆ្នាំទី២ដល់ទី៥)។ ការពិនិត្យបច្ចេកទេសនិងហិរញ្ញវត្ថុនៃសំណើរបស់ដៃគូទាំងអស់ត្រូវបានអនុវត្តដោយ PMU បន្ទាប់ពីដំណើរការអនុម័ត របស់ GSSD ហើយត្រូវបានកែសម្រួលដោយដៃគូនានាតាមការចាំបាច់បន្ទាប់ពីការប្រជុំស្រុះស្រួលគ្នា។ សំណើ គម្រោងរបស់អង្គការភាគច្រើនត្រូវបានស្នើឱ្យកែសម្រួលជាថ្មី ដែលPMU បានគាំទ្របច្ចេកទេសច្រើនដល់GDLC GDANCP និងនាយកដ្ឋានជីវៈចម្រុះដើម្បីអាចបញ្ចប់ការកែសម្រួលរៀបចំ និងកែសម្រួលសំណើគម្រោង។ លើសពីនេះ ទៀត តួនាទីក្នុងការអនុវត្តសកម្មភាពជាក់លាក់របស់ភ្នាក់ងារអនុវត្តខ្លះ ត្រូវបានកែសម្រួលតាមរយៈការពិគ្រោះពិភាក្សា ជាមួយភាគីពាក់ព័ន្ធ។ ឧទាហរណ៍ នាយកដ្ឋានជីវៈចម្រុះទទួលភារកិច្ចច្រើនជាងមុនក្នុងការអនុវត្តសកម្មភាពទំនាក់ ទំនងដែលស្ថិតនៅក្រោមការផ្តល់ជំនួយបច្ចេកទេសពីអង្គការ Live and Learn។ នៅពេលដែលUN Environment ឯកភាពលើសំណើសកម្មភាពលម្អិត និងថវិការបស់អង្គការនិមួយៗ ក្រុមការងារPMU នឹងចុះកិច្ចព្រមព្រៀងជាមួយ ដៃគូភ្លាម អនុវត្តតាមទំរង់កិច្ចព្រមព្រៀង និងជំនួយស្មារតីទូទាត់ថវិកា ដែលអាចណែនាំដល់អង្គការដៃគូពីច្បាប់ នីតិវិធី និងទំរង់សម្រាប់របាយការណ៍។ អនុវត្តតាមនីតិវិធីរបស់GSSD ក្រុមការងារបានបញ្ចប់ការវាយតម្លៃសមត្ថភាពអនុវត្ត គម្រោងរបស់អង្គការដៃគូ ដើម្បីធានាថាដៃគូអនុវត្តទាំងនោះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្ត និងគ្រប់គ្រងថវិកា។ អង្គការទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្ត ហើយក្រុមការងារ PMU និងផ្តល់ការណែនាំបន្ថែមពីក្របខណ្ឌ អនុវត្តថវិការបស់GSSD ក្រោយពេលដែលកិច្ចព្រមព្រៀងបានចុះហត្ថលេខា។ កំឡុងពេលនេះដែរ ក្របខណ្ឌអនុវត្ត M&E របស់គម្រោងត្រូវបានរៀបចំបញ្ចប់ និងទទួលបានការឯកភាពពីUNEP ហើយឯកសាររបាយការណ៍បឋមត្រូវបាន កែសម្រួល និងឯកសារផ្សេងទៀតត្រូវបានផលិតតាមរយៈការផ្តល់ធាតុចូលពី UN Environment។ គម្រោងក៏បាន ពង្រឹងផ្សារភ្ជាប់ទំនាក់ទំនងជាមួយគម្រោងនានាដើម្បីធានាថាថវិកាជំនួយត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ ថ្មីៗនេះ ក្រុមការងារPMU បានជួបពិភាក្សាជាមួយភ្នាក់ងារអនុវត្តគម្រោងនៅថ្នាក់ខេត្តដើម្បីឯកភាពលើសកម្មភាព មួយចំនួនដែលគាំទ្រផ្នែកហិរញ្ញវត្ថុពីគម្រោងCAMPAS។ រដ្ឋបាលខេត្តមណ្ឌលគិរី មន្ទីរបរិស្ថានខេត្ត មន្ទីរកិច្ចការនារី នឹងចុះកិច្ចព្រមព្រៀងអនុវត្តសកម្មភាពផ្អែកលើលទ្ធផល(Outputs-Based) នៅក្នុងឆ្នាំ២០១៨។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

4

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

- UNEP/GEF

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 246.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 126.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 4.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 115.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 983.8 | 0.0 | 1,435.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 72.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 1.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 22.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 887.7 | 0.0 | 1,435.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 1,230.7 | 0.0 | 1,435.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 1,230.7 | 0.0 | 1,435.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Global Fund | 1,230.7 | 0.0 | 1,435.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 1,230.7 | 0.0 | 1,435.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: